អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០

## សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក. សូមធ្វើការកែតម្រូវនូវសេចក្តីរាយការណ៍ព័ត៌មានដែលមានលក្ខណៈខុសឆ្គង និងភ័ន្តច្រឡំមួយចំនួន ក្នុងសេចក្តីថា *"សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មី៥នាក់ទៀត"* (ឌឹ ឃែមបូឌា ដេលី ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០) និង *"ចៅក្រមសាលាក្តីខ្មែរក្រហមមិនបានចុះហត្ថលេខាឲ្យមានការស៊ើបអង្កេតថ្មីទេ"* (ឌឹ ឃែមបូឌា ដេលី ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០) ។

ដើម្បីឲ្យមានតម្លាភាព សហចៅក្រមស៊ើបអង្កេតបានសម្រេចធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលិខិតទំនាក់ទំនងដែលបានធ្វើក្នុងពេលថ្មីៗទាក់ទងនឹងបញ្ហាខាងលើនេះ និងប្រកាសថា នាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់ទុកថា មានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របនៃចំណាត់ការស៊ើបសួរ។ ហេតុដូចនេះ ចំពោះផែនការនៃការស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ ដែលរៀបចំសម្រាប់រយៈពេលរហូតដល់ដំណាច់ឆ្នាំនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារនេះតែម្នាក់ឯង ដោយអនុលោមទៅតាមបញ្ញត្តិនៃវិធាន ៧២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ។

(ជូនភ្ជាប់៖ អនុស្សារណៈពីចៅក្រម ម៉ាសែល ឡឺម៉ុងដ៍ ជូនចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី ០២ មិថុនា និងអនុស្សារណៈពីចៅក្រម យូ ប៊ុនឡេង ជូនចៅក្រម ម៉ាសែល ឡឺម៉ុងដ៍ ចុះថ្ងៃទី ០៨ មិថុនា)